ក្រសួងពាណិជ្ជកម្ម
Ministry of Commerce

British Embassy
Phnom Penh

<u>សេចក្តីប្រកាសព័ត៌មានរួម</u>

**ថ្ងៃទី២៩ ខែមករា ឆ្នាំ២០២៦**

---

**ព្រះរាជាណាចក្រកម្ពុជា និងចក្រភពអង់គ្លេស ពង្រឹងភាពជាដៃគូសេដ្ឋកិច្ចនៅក្នុងវេទិកាពាណិជ្ជកម្ម និងវិនិយោគរួមគ្នារវាងកម្ពុជា-ចក្រភពអង់គ្លេស លើកទី៣**

រាជធានីភ្នំពេញ – នៅថ្ងៃនេះ ក្រសួងពាណិជ្ជកម្មនៃព្រះរាជាណាចក្រកម្ពុជា និងស្ថានទូតអង់គ្លេសប្រចាំនៅកម្ពុជា នឹងធ្វើជាម្ចាស់ផ្ទះរួមគ្នាក្នុងការរៀបចំវេទិកាពាណិជ្ជកម្ម និងវិនិយោគរួមគ្នារវាងកម្ពុជា-ចក្រភពអង់គ្លេស លើកទី៣ (Third JTIF)។

តាមរយៈការរៀបចំវេទិកាពាណិជ្ជកម្ម និងវិនិយោគរួមគ្នារវាងកម្ពុជា-ចក្រភពអង់គ្លេស លើកទី៣ ក្រោមប្រធានបទ «ទស្សនវិស័យកម្ពុជា-ចក្រភពអង់គ្លេស៖ ភាពជាដៃគូឆ្ពោះទៅមុខ ក្នុងបរិបទនៃការផ្លាស់ប្តូរសកល» ប្រទេសទាំងពីរបញ្ជាក់សារជាថ្មីនូវការប្តេជ្ញាចិត្តរបស់ខ្លួនក្នុងការពង្រឹងកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ច ការលើកកម្ពស់កំណើនប្រកបដោយចីរភាព និងការបង្កើតកាលានុវត្តភាពថ្មីៗសម្រាប់ធុរកិច្ច។

វេទិកានេះរៀបចំឡើងក្នុងខណៈពេលដ៏សំខាន់ក្នុងស្ថានភាពនៃការអភិវឌ្ឍ និងមហិច្ឆតារបស់ប្រទេសកម្ពុជា ខណៈពេលដែលប្រទេសកម្ពុជាកំពុងបោះជំហានឆ្ពោះទៅកាន់ការចាកចេញពីប្រទេសអភិវឌ្ឍន៍តិចតួចនៅឆ្នាំ២០២៩ និងការប្រកាសរបស់កម្ពុជាក្នុងការដាក់ពាក្យចូលរួមកិច្ចព្រមព្រៀងគ្រប់ជ្រុងជ្រោយ និងជឿនលឿនសម្រាប់ភាពជាដៃគូអន្តរប៉ាស៊ីហ្វិក (CPTPP) នាពេលថ្មីៗនេះ។ ប្រទេសកម្ពុជា និងចក្រភពអង់គ្លេសបានគូសបញ្ជាក់ពីការប្តេជ្ញាចិត្តរួមគ្នារបស់ខ្លួន ចំពោះការធ្វើពាណិជ្ជកម្មដែលអាចព្យាករណ៍បាន និងផ្អែកលើច្បាប់ ជាមូលដ្ឋានសម្រាប់កំណើន និងទំនុកចិត្តរបស់វិនិយោគិន។

វេទិកាពាណិជ្ជកម្ម និងវិនិយោគរួមគ្នា គឺជាវេទិកាទ្វេភាគីចម្បងរវាងប្រទេសកម្ពុជា និងចក្រភពអង់គ្លេស សម្រាប់កិច្ចសន្ទនាគោលនយោបាយ កិច្ចសហប្រតិបត្តិការលើច្រកចូលទីផ្សារ និងការចូលរួមរបស់វិស័យសាធារណៈ-ឯកជន។ វេទិកានេះប្រមូលផ្តុំមន្ត្រីជាន់ខ្ពស់ អ្នករៀបចំបទប្បញ្ញត្តិ វិនិយោគិន និងថ្នាក់ដឹកនាំអាជីវកម្ម ដើម្បីជំរុញពាណិជ្ជកម្មទ្វេភាគី កាត់បន្ថយរបាំង និងលើកកម្ពស់ភាពជាដៃគូពាណិជ្ជកម្ម និងវិនិយោគរយៈពេលវែងរវាងប្រទេសទាំងពីរ។

ក្រសួងពាណិជ្ជកម្ម

G /-

កិច្ចប្រជុំ JTIF លើកទី៣ នឹងគូសត្រាយផ្លូវដើម្បីប្រែក្លាយកាលានុវត្តភាពទៅជាការធ្វើពាណិជ្ជកម្ម និង វិនិយោគឱ្យបានកាន់តែច្រើនរវាងប្រទេសកម្ពុជា និងចក្រភពអង់គ្លេស តាមរយៈកិច្ចសហប្រតិបត្តិការផ្នែកបទប្បញ្ញត្តិ ភាពជាដៃគូនិងគំនិតផ្តួចផ្តើមនានាដើម្បីពង្រឹងទីផ្សារ ការវិនិយោគ និងការប្រើប្រាស់ប្រកទីផ្សារ។ កិច្ចសន្ទនារបស់យើងមានគោលបំណងធ្វើឱ្យមានការធ្វើពាណិជ្ជកម្ម និងការវិនិយោគកើតឡើងជារូបរាងពិតប្រាកដ តាមរយៈការលុបបំបាត់ឧបសគ្គ និងបង្កើនការប្រើប្រាស់ក្របខណ្ឌអនុគ្រោះពាណិជ្ជកម្ម ដូចជាគម្រោងពាណិជ្ជកម្មប្រទេសកំពុងអភិវឌ្ឍន៍ (DCTS)។

វេទិកានេះរំលេចនូវវឌ្ឍនភាពសម្រេចបានជាក់ស្តែងចាប់តាំងពីវេទិកា JTIF លើកទី២ ដែលបានរៀបចំឡើងកាលពីខែវិច្ឆិកា ឆ្នាំ២០២៤ ដែលក្នុងនោះរួមមាន៖ ការពង្រឹងការសម្របសម្រួលគោលនយោបាយដែលគ្របដណ្តប់លើវិស័យជាអត្ថប្រយោជន៍សំខាន់ៗរបស់ប្រទេសទាំងពីរ រួមមាន ការសម្របសម្រួលការនាំចេញ គោលនយោបាយពន្ធដារ ការដាក់ចេញប្រភេទទិដ្ឋាការលើកទឹកចិត្តវិនិយោគ រួមជាមួយនឹងការកសាងសមត្ថភាពនិងអភិវឌ្ឍជំនាញ ការរៀបចំកិច្ចសន្ទនាស្តីពីការអភិវឌ្ឍទីផ្សារមូលធននិងកិច្ចសហប្រតិបត្តិការគយ និងការចូលរួមកាន់តែស៊ីជម្រៅរវាងធុរកិច្ចអង់គ្លេស និងកម្ពុជាក្នុងសេវាកម្មហិរញ្ញវត្ថុ កម្មន្តសាល ការកែច្នៃកសិកម្ម បច្ចេកវិទ្យា និងការផ្តល់សេវាកម្មផ្នែកច្បាប់ និងវិជ្ជាជីវៈ។

**លោកជំទាវ ចម និម្មល រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្មកម្ពុជា បានមានប្រសាសន៍ថា៖**

*«វេទិកាពាណិជ្ជកម្ម និងវិនិយោគរួមគ្នាបានក្លាយជាថ្នាលចម្បងក្នុងការលើកកម្ពស់ភាពជាដៃគូពាណិជ្ជកម្មនិងវិនិយោគរវាងកម្ពុជានិងចក្រភពអង់គ្លេស។ ដោយផ្តោតលើការអនុវត្តបានជាក់ស្តែងនិងការចូលរួមដោយសកម្មនិងជាប្រចាំ វេទិកានេះបានប្រមូលផ្តុំអ្នករៀបចំគោលនយោបាយ តួអង្គពាក់ព័ន្ធ និងភាគីវិស័យឯកជន ដើម្បីរួមគ្នាដោះស្រាយបញ្ហាប្រឈម និងកាលានុវត្តភាព ដែលបង្កើតបានជាមូលដ្ឋានគ្រឹះដ៏រឹងមាំ ឈានទៅសម្រេចបានសមិទ្ធផលសម្រាប់ការធ្វើពាណិជ្ជកម្ម និងវិនិយោគឱ្យកាន់តែមានភាពទូលំទូលាយ និងល្អប្រសើរជាងមុន។*

*តាមរយៈការពិនិត្យមើលវឌ្ឍនភាពជាក់ស្តែងដែលយើងសម្រេចបាន និងការកំណត់ទិសដៅបន្ត ខ្ញុំមានការរំពឹងទុកយ៉ាងធំធេងចំពោះវេទិកា JTIF លើកទី៣ ដែលលទ្ធផលសម្រេចបាននៅក្នុងវេទិកានេះ ខ្ញុំជឿជាក់ថានឹងអាចបង្កើតនូវកាលានុវត្តភាពថ្មីៗ ដើម្បីជំរុញនិងពង្រឹងភាពជាដៃគូពាណិជ្ជកម្ម និងវិនិយោគរវាងប្រទេសទាំងពីរ នៅក្នុងបរិបទសកលលោកដែលកំពុងផ្លាស់ប្តូរជាបន្តបន្ទាប់។»*

**លោកស្រី Rhiannon Harries អនុប្រធានពាណិជ្ជកម្មទទួលបន្ទុកតំបន់អាស៊ីប៉ាស៊ីហ្វិក (អាស៊ីអាគ្នេយ៍) បានមានប្រសាសន៍ថា៖**

*«វេទិកាពាណិជ្ជកម្ម និងវិនិយោគរួមគ្នារវាងចក្រភពអង់គ្លេស និងកម្ពុជា គឺជាឱកាសដ៏សំខាន់មួយសម្រាប់ប្រទេសរបស់យើង ដើម្បីពង្រឹងទំនាក់ទំនងសេដ្ឋកិច្ចរបស់យើង ដោះស្រាយបញ្ហាប្រឈមរួម*

ក្រសួងពាណិជ្ជកម្ម

G-K

*គ្នា និងរៀបចំផែនការសម្រាប់អនាគតប្រកបដោយចីរភាព។ វាឆ្លុះបញ្ចាំងពីការចូលរួមកាន់តែខ្លាំងឡើងរបស់យើងជាមួយតំបន់អាស៊ីអាគ្នេយ៍ដ៏ទូលំទូលាយ ដែលយើងចែករំលែកទំនាក់ទំនងពាណិជ្ជកម្មប្រចាំឆ្នាំចំនួន ៥៧ពាន់លានផោន ដែលបញ្ជាក់ពីការប្តេជ្ញាចិត្តរបស់យើងក្នុងនាមជាដៃគូសន្ទនាថ្មីបំផុតរបស់អាស៊ាន។»*

**ឯកឧត្តម Dominic Williams MBE ឯកអគ្គរាជទូតអង់គ្លេសប្រចាំនៅកម្ពុជា បានមានប្រសាសន៍ថា៖**

*«ពាណិជ្ជកម្ម និងការវិនិយោគ គឺជាផ្នែកមួយដ៏សំខាន់នៃទំនាក់ទំនងរវាងចក្រភពអង់គ្លេស និងកម្ពុជា។ យើងទាំងពីរជាប្រទេសដែលមានសេដ្ឋកិច្ចបើកចំហរ និងផ្តោតលើការនាំចេញ ដែលជឿជាក់លើប្រព័ន្ធពាណិជ្ជកម្មដែលមានមូលដ្ឋានលើច្បាប់អន្តរជាតិ។ យើងទាំងពីរមានបំណងចង់ពង្រឹងភាពជាដៃគូសេដ្ឋកិច្ចរបស់យើង និងផ្តល់នូវវិបុលភាព និងការងារកាន់តែច្រើនដល់ប្រជាជននៃប្រទេសទាំងពីរ។*

*ខ្ញុំមានសេចក្តីសោមនស្សរីករាយជាមួយនឹងកិច្ចសហការយ៉ាងជិតស្និទ្ធរបស់យើងជាមួយរាជរដ្ឋាភិបាលលើរបៀបវារៈនេះ ហើយយើងរីករាយដែលយើងអាចមកជួបជុំគ្នាជាមួយវិស័យឯកជនរៀងៗខ្លួនរបស់យើងនៅក្នុងវេទិកាពាណិជ្ជកម្ម និងវិនិយោគរួមគ្នា ក្នុងការកំណត់ជំហានជាក់ស្តែងដើម្បីសម្រួលដល់ពាណិជ្ជកម្ម និងការវិនិយោគកាន់តែច្រើន។»*

**កំណត់ចំណាំសម្រាប់អ្នកកែសម្រួល**

- វេទិកាពាណិជ្ជកម្ម និងវិនិយោគរួមគ្នារវាងចក្រភពអង់គ្លេស និងកម្ពុជា ត្រូវបានបង្កើតឡើងដើម្បីពង្រឹងទំនាក់ទំនងពាណិជ្ជកម្ម និងវិនិយោគរវាងប្រទេសទាំងពីរ។ វេទិកានេះប្រមូលផ្តុំនូវតំណាងរាជរដ្ឋាភិបាល និងវិស័យឯកជនរបស់ចក្រភពអង់គ្លេស និងកម្ពុជា ដើម្បីជំរុញកំណើនប្រកបដោយចីរភាព និងបរិយាបន្នតាមរយៈភាពជាដៃគូរយៈពេលវែង កិច្ចសន្ទនាគោលនយោបាយ និងកិច្ចសហការអាជីវកម្ម។
- ក្នុងឆ្នាំ ២០២៥ ទំហំពាណិជ្ជកម្មទ្វេភាគីរវាងកម្ពុជា និងចក្រភពអង់គ្លេស បានកើនឡើងលើស ១ ពាន់លានដុល្លារអាមេរិក។
- គម្រោងពាណិជ្ជកម្មប្រទេសកំពុងអភិវឌ្ឍន៍ (DCTS) គឺជាកម្មវិធីអនុគ្រោះពាណិជ្ជកម្មរបស់ចក្រភពអង់គ្លេស ដែលត្រូវបានបង្កើតឡើងដើម្បីគាំទ្រដល់ប្រទេសកំពុងអភិវឌ្ឍន៍។ បច្ចុប្បន្នប្រទេសកម្ពុជាទទួលបានអត្ថប្រយោជន៍កម្រិតខ្ពស់បំផុតពី DCTS ក្នុងនាមជាប្រទេសអភិវឌ្ឍន៍តិចតួច (LDC) ដែលគម្រោងនេះផ្តល់ភាពអនុគ្រោះពន្ធចូលទីផ្សារចក្រភពអង់គ្លេសដោយទទួលបានអត្រាពន្ធសូន្យ និងមិនគិតបរិមាណ សម្រាប់មុខទំនិញភាគច្រើន។ ក្រោមគម្រោងនេះ ប្រទេសកម្ពុជានឹងបន្តទទួលបានការអនុគ្រោះពន្ធក្នុងអំឡុងពេលអន្តរកាលនៃការចាក

ចេញពីប្រទេសអភិវឌ្ឍន៍តិចតួច ដោយអត្ថប្រយោជន៍ទាំងនេះនឹងនៅតែមានសុពលភាពរហូតដល់ឆ្នាំ២០៣២។ បន្ទាប់មក ប្រទេសកម្ពុជាអាចបន្តទទួលបានការអនុគ្រោះពន្ធចូលទៅទីផ្សារចក្រភពអង់គ្លេស ក្រោមកម្រិត "Enhanced" របស់ DCTS ដែលគ្របដណ្តប់លើមុខទំនិញជាច្រើន។

- នៅក្នុងខែវិច្ឆិកា ឆ្នាំ២០២៤ ស្ថាប័នហិរញ្ញប្បទានសម្រាប់ការនាំចេញរបស់ចក្រភពអង់គ្លេស (UKEF) និងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ បានចុះហត្ថលេខាលើអនុស្សរណៈនៃការយោគយល់គ្នា ដើម្បីពង្រីកជម្រើសហិរញ្ញប្បទានសម្រាប់គម្រោងហេដ្ឋារចនាសម្ព័ន្ធ និងគម្រោងអភិវឌ្ឍន៍ប្រកបដោយចីរភាពរបស់កម្ពុជា។
- ចក្រភពអង់គ្លេសគឺជាដៃគូមួយក្នុងចំណោមដៃគូដំបូងបំផុត ដែលគាំទ្រដល់ការត្រៀមខ្លួនរបស់កម្ពុជា ក្នុងការចាកចេញពីប្រទេសអភិវឌ្ឍន៍តិចតួច ដែលរួមមាន ជំនួយបច្ចេកទេស និងការសន្ទនាគោលនយោបាយ។
- ប្រទេសកម្ពុជាបានប្រកាសពីការដាក់ពាក្យសុំចូលជាសមាជិកនៃ CPTPP ដែលជាក្របខណ្ឌពាណិជ្ជកម្មក្នុងតំបន់ដ៏គ្រប់ជ្រុងជ្រោយបំផុតនៅក្នុងតំបន់អាស៊ីប៉ាស៊ីហ្វិក។
- បច្ចុប្បន្នត្រូវបានចាត់ថ្នាក់ជាប្រទេសអភិវឌ្ឍន៍តិចតួច (LDC) ដោយអង្គការសហប្រជាជាតិ ប្រទេសកម្ពុជាគ្រោងនឹងចាកចេញពីប្រទេសអភិវឌ្ឍន៍តិចតួច នៅឆ្នាំ២០២៩។ ការចាកចេញពីប្រទេសអភិវឌ្ឍន៍តិចតួច គឺជាដំណើរការដែលប្រទេសមួយផ្លាស់ប្តូរចេញពីចំណាត់ថ្នាក់នេះ ដែលជាការឆ្លុះបញ្ចាំងពីការអភិវឌ្ឍសេដ្ឋកិច្ចកាន់តែល្អប្រសើរឡើង។ ការផ្លាស់ប្តូរនេះនឹងប៉ះពាល់ដល់ការទទួលបានភាពអនុគ្រោះពាណិជ្ជកម្ម និងតម្រូវឱ្យមានការធ្វើផែនការដោយប្រុងប្រយ័ត្នដើម្បីរក្សាភាពប្រកួតប្រជែង។

**បញ្ចប់**

**សម្រាប់ការសាកសួរព័ត៌មានពីប្រព័ន្ធផ្សព្វផ្សាយ សូមទំនាក់ទំនង៖**

លេខទូរស័ព្ទទំនាក់ទំនងសាធារណៈរបស់ក្រសួងពាណិជ្ជកម្ម៖ **១២៦៦**

ស្ថានទូតចក្រភពអង់គ្លេសប្រចាំនៅកម្ពុជា៖ ukincambodia@fcdo.gov.uk

ក្រសួងពាណិជ្ជកម្ម ព្រះរាជាណាចក្រកម្ពុជា